# ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា

*ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣*

ម.ស.ម.ក បានឃ្លាំមើលការវិវឌ្ឍដែលពាក់ព័ន្ធនឹង**សិទ្ធិសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន**នៅកម្ពុជា ចាប់ពីខែកញ្ញា ឆ្នាំ២០២២ ដល់ខែសីហា ឆ្នាំ២០២៣។

ការស្រាវជ្រាវបានបង្ហាញថាសិទ្ធិទាំងនេះបាន**រងការវាយប្រហារ** ដោយដៅមុខសញ្ញាលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សដោយសារការអនុវត្តការងាររាយការណ៍ និងការតស៊ូមតិដ៏មានសារៈសំខាន់របស់ពួកគេ។

រដ្ឋាភិបាលក៏បានបន្តនិន្នាការរឹតត្បិតដោយហួសហេតុលើ**សេរីភាពបញ្ចេញមតិ និងបំបិទសំឡេងរិះគន់**ដែលជាការគាបសង្កត់**កាន់តែធ្ងន់ធ្ងរ**នៅមុនការបោះឆ្នោតថ្នាក់ជាតិខែកក្កដា ឆ្នាំ២០២៣។

| សេរីភាពនៅលើពិភពលោកឆ្នាំ ២០២៣ | សេរីភាពតាមអ៊ីនធឺណិតឆ្នាំ ២០២៣ | សន្ទស្សន៍សេរីភាពសារព័ត៌មាន ឆ្នាំ២០២៣ | សន្ទស្សន៍ប្រជាធិបតេយ្យឆ្នាំ ២០២២ |
|---|---|---|---|
| ២៤/១០០ | ៤៤/១០០ | ៤២,០២/១០០ | ៣,១៨/១០ |
| គ្មានសេរីភាព | សេរីភាពដោយផ្នែក | ស្ថានភាពអាក្រក់ | ផ្តាច់ការ |

## *តាមការឃ្លាំមើល៖ អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សរងការវាយប្រហារ*

### អ្នកសារព័ត៌មានចំនួន១៦នាក់ និងអ្នកការពារសិទ្ធិមនុស្សចំនួន១០០នាក់ ប្រឈមនឹងវិធានការផ្លូវច្បាប់




### អាជ្ញាបណ្ណសារព័ត៌មានចំនួន៥ ត្រូវបានដកហូត

- ១៦ មករា ២០២៣ សារព័ត៌មានខ្មែរខូវីធីវី
- ១៣ កុម្ភៈ ២០២៣ សារព័ត៌មានវីអូឌី
- ១៦ មីនា ២០២៣
  - សហព័ន្ធអ្នកសារព័ត៌មានកម្ពុជា-អាស៊ាន
  - សារព័ត៌មានរស្មីកំពង់ចាម
  - សារព័ត៌មានដំណឹងក្នុងស្រុក

### គេហទំព័រសារព័ត៌មានត្រូវបានបិទខ្ទប់

កំណត់ត្រា | វិទ្យុអាស៊ីសេរី | ខេមបូឌាដេលី

## *ការយាយីតាមផ្លូវតុលាការលើករណីលេចធ្លោមួយចំនួន*

### សមាជិកសហជីពណាហ្គាវើលដ៍

ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣

ផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ

កញ្ញា ឈឹម ស៊ីថរ រយៈពេលពីរឆ្នាំ។

កញ្ញា ឈឹម សុខន អ្នកស្រី ហៃ សុភាព អ្នកស្រី ឃ្លាំង សុបិន្ត អ្នកស្រី សុន ស្រីពេជ្រ កញ្ញា ទូច សេរីមាស រយៈពេល១,៥ ឆ្នាំ

លោក សុខ ណារិទ្ធិ លោក សុខ គង្គារ អ្នកស្រី រី សុវណ្ណឌី៖ ១ឆ្នាំ ដោយការព្យួរ។

### សកម្មជនដីធ្លីខេត្តកោះកុង

លោក ឆាន់ ឈឿន អ្នកស្រី ដេត ហួរ អ្នកស្រី អ៊ើប វី អ្នកស្រី អឹប តឹង លោក ហេង ជ័យ អ្នកស្រី អ៊ិន ធូ អ្នកស្រី កើត នៅ លោក គង់ ម៉ែន លោក ពួ ហួន លោក សុខ ជ័យ

១៥ សីហា ២០២៣

ផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេលមួយឆ្នាំ និងបង់សំណង ចំនួន៤០លានរៀល។

### បុគ្គលិកសមាគមអាដហុកទាំង៥នាក់

**លោក នី សុខា លោក យី សុខសាន្ត អ្នកស្រី លឹម មុន្នី លោក ណៃ វ៉ង់ដា លោក នី ចរិយា**

១៨ វិច្ឆិកា ២០២២

តម្កល់ការផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេលប្រាំឆ្នាំ។

*"ជាការចោទប្រកាន់មានលក្ខណៈប្រឌិត និងនយោបាយ"*

**អង្គការឃ្លាំមើលសិទ្ធិមនុស្ស។**

### អ្នកសារព័ត៌មាន

**លោក សែម ឌីយ៉ា៖** ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេលមួយឆ្នាំ។

**លោក ប៉ែន នួន៖** ថ្ងៃទី២៣ មករា ២០២៣ តម្កល់ការផ្តន្ទាទោសពិន័យ និងសំណងជាប្រាក់ចំនួន៨៥លានរៀល។

**លោក កៅ ពិសិដ្ឋ៖** ថ្ងៃទី០១ កុម្ភៈ ២០២៣ តម្កល់ការផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេលពីរឆ្នាំ។



CC BY NC SA

ខែវិច្ឆិកា ឆ្នាំ២០២៣